សាលាដំបូងរាជធានីភ្នំពេញ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងរាជធានីភ្នំពេញ

សាលក្រមព្រហ្មទណ្ឌលេខ ៤០៣ "ក្រ៦ស" បានបើកសវនាការជាសាធារណៈនៅថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២២ វេលាម៉ោង៨ ព្រឹកនៅ

ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០២២ សាលសវនាការទី៤ ដោយមានសមាសភាព៖

សំណុំរឿងព្រហ្មទណ្ឌលេខ ៤៦៧៣
ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២១
សំណុំរឿងស៊ើបសួរលេខ ៣៥៥៧
ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០២១
សំណុំរឿងជំនុំជម្រះលេខ ១១១៥
ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២

### ក្រុមប្រឹក្សាជំនុំជម្រះ

លោក [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ជាប្រធានក្រុមប្រឹក្សា
លោក [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ជាចៅក្រមប្រឹក្សា
លោកស្រី [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ជាចៅក្រមប្រឹក្សា

### តំណាងអយ្យការ

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

### ក្រឡាបញ្ជីសវនាការ

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ៤៦៧៣ ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២១ ដែលមានជនជាប់ចោទ៖

១-ឈ្មោះ [redacted] ចនា ហៅ សីហា ភេទប្រុស អាយុ ២៧ ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិតាណ ឃុំតេជោ ស្រុកកំពង់រោទ៍ ខេត្តស្វាយរៀង អាសយដ្ឋានស្នាក់នៅ [redacted] សង្កាត់កំបូល ខណ្ឌកំបូល រាជធានីភ្នំពេញ ប្រពន្ធឈ្មោះ [redacted] មានកូន ១ នាក់ ឪពុកឈ្មោះ [redacted] "រ" ម្តាយឈ្មោះ [redacted] "រ" ទោសពីមុន គ្មាន។

-ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៧៩០៨ "ឃ" ដឃដ ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០២១។

មេធាវីការពារក្តីលោកមេធាវី **ឡាយ ឡុងឌី**។

១-ឈ្មោះ [redacted] ខាសនា ហៅ ស្លា ភេទប្រុស អាយុ ២៨ ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើតនៅសង្កាត់ឫស្សីកែវ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ អាសយដ្ឋានស្នាក់ [redacted] សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ប្រពន្ធឈ្មោះ [redacted] គ្មានកូន ឪពុកឈ្មោះ [redacted]" ម្តាយឈ្មោះ [redacted] "រ" ទោសពីមុន គ្មាន។

Scanned with CamScanner

-ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៧៩០៧ "យ" ជបរជ ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០២១។

មេធាវីការពារក្ដីលោកមេធាវី [redacted] ឡុងឌី។

ជាប់ចោទពីបទ **លួចមានស្ថានទម្ងន់ទោស** តាមបញ្ញត្តិមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ ប្រព្រឹត្តនៅចំណុចចំណុចផ្លូវប្រសព្វស្ពឺបរេអិន ផ្លូវលេខ១២៨ សង្កាត់ផ្សារដេប៉ូទី៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ កាលពីថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០២១ តាមដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ១២០៤ "យ" ដ.ជ ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងរាជធានីភ្នំពេញ។

-ជនរងគ្រោះឈ្មោះ [redacted] ធឿន ភេទស្រី អាយុ ៣៧ ឆ្នាំ ជនជាតិខ្មែរ អាសយដ្ឋាននៅផ្ទះលេខ៧ ផ្លូវលេខ១២២ សង្កាត់ផ្សារដេប៉ូទី៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ។

## <u>អង្គហេតុនៃរឿងមានដូចតទៅ</u>

កាលពីថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០២១ វេលាម៉ោង ២០ និង២០ នាទី ជនជាប់ចោទឈ្មោះ [redacted] រចនា និងជនជាប់ចោទឈ្មោះ [redacted] វាសនា បានជិះម៉ូតូមួយគ្រឿង ម៉ាក វីវ៉ា ដើម្បីធ្វើសកម្មភាពឆក់ទ្រព្យសម្បត្តិរបស់អ្នកដទៃ ដោយជនជាប់ចោទឈ្មោះ [redacted] រចនា ជាអ្នកបើកបរម៉ូតូ និងជនជាប់ចោទឈ្មោះ [redacted] វាសនា ជិះនៅខាងក្រោយ ដល់ចំណុចកើតហេតុត្រង់ផ្លូវប្រសព្វស្ពឺបរេអិន បានឃើញជនរងគ្រោះកំពុងធ្វើដំណើរថ្មើរជើង ជនជាប់ចោទឈ្មោះ [redacted] រចនា បានជិះអែបទៅខាងស្ដាំដៃរបស់ជនរងគ្រោះ ហើយជនជាប់ចោទឈ្មោះ [redacted] វាសនា បានធ្វើសកម្មភាពឆក់កាបូបស្ពាយ ដែលជនរងគ្រោះបានស្ពាយជាប់នឹងស្មា បណ្ដាលឱ្យជនរងគ្រោះដួលទៅលើថ្នល់រងរបួសស្រាល ចំណែកជនជាប់ចោទទាំងពីរនាក់បានជិះម៉ូតូរត់គេចខ្លួនចេញពីកន្លែងកើតហេតុ ប៉ុន្តែជនជាប់ចោទត្រូវសមត្ថកិច្ចដេញចាប់ឃាត់ខ្លួនបានភ្លាមៗ និងបានដកហូតកាបូបស្ពាយ ព្រមទាំងសម្ភារៈ ប្រគល់ឱ្យជនរងគ្រោះវិញ។

-បានឃើញ របាយការណ៍លេខ ១៣៣ របក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២១ របស់ការិយាល័យព្រហ្មទណ្ឌកំរិតស្រាល នៃនាយកដ្ឋាននគរបាលព្រហ្មទណ្ឌ។

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ៣៦១៥ អ.យ.ណ ចុះថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០២១ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ ៧២៨ អ.យ.ណ ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ១២០៤ "យ" ដ.ជ ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងរាជធានីភ្នំពេញ។

## <u>នាពេលសវនាការ</u>

-ជនជាប់ចោទឈ្មោះ [redacted] រចនា បានឆ្លើយថា ខ្លួនបានប្រព្រឹត្តដូចការចោទប្រកាន់មែន នៅថ្ងៃកើត

Scanned with CamScanner

ហេតុខ្លួននិងឈ្មោះ [redacted] វាសនា បន្ទាប់ពីលេងហ្គេមបាញ់ត្រី អស់ប្រាក់បាននាំគ្នាជិះម៉ូតូ មួយ គ្រឿង ម៉ាក វីវ៉ា ដើម្បីធ្វើសកម្មភាពឆក់ ដោយខ្លួនជាអ្នកបើកបរម៉ូតូ ពេលដល់កន្លែងកើតហេតុបានឃើញជនរងគ្រោះឈប់ម៉ូតូ ចូលទៅទិញម្ហូប ដោយជនរងគ្រោះបានទុកកាបូបស្ពាយ នៅលើម៉ូតូ ខ្លួនបានឈប់ម៉ូតូ ហើយឈ្មោះ [redacted] វាសនា បានដើរចូលទៅលួចយកកាបូបស្ពាយនោះ បន្ទាប់មកពួកខ្លួនបានជិះម៉ូតូរត់គេចខ្លួន ប៉ុន្តែត្រូវសមត្ថកិច្ចជិះម៉ូតូដេញតាម និងចាប់ឃាត់ខ្លួនបានភ្លាមៗតែម្តង។

-ជនជាប់ចោទឈ្មោះ [redacted] វាសនា បានឆ្លើយថា ខ្លួនបានប្រព្រឹត្តដូចការចោទប្រកាន់មែន នៅថ្ងៃកើតហេតុខ្លួននិងឈ្មោះ [redacted] វាសនា បន្ទាប់ពីលេងហ្គេមបាញ់ត្រី អស់ប្រាក់បាននាំគ្នាជិះម៉ូតូ មួយ គ្រឿង ម៉ាក វីវ៉ា ដើម្បីធ្វើសកម្មភាពឆក់ ដោយឈ្មោះ [redacted] វាសនា ជាអ្នកបើកបរម៉ូតូ ចំណែកខ្លួនជិះនៅខាងក្រោយ ពេលដល់កន្លែងកើតហេតុបានឃើញជនរងគ្រោះឈប់ម៉ូតូ ចូលទៅទិញម្ហូប ដោយជនរងគ្រោះបានទុកកាបូបស្ពាយ នៅលើម៉ូតូ ឈ្មោះ [redacted] វាសនា បានឈប់ម៉ូតូ ហើយខ្លួនបានដើរចូលទៅលួចយកកាបូបស្ពាយនោះតែម្តង បន្ទាប់មកពួកខ្លួនបានជិះម៉ូតូរត់គេចខ្លួន ប៉ុន្តែត្រូវសមត្ថកិច្ចជិះដេញតាម និងចាប់ឃាត់ខ្លួនបានភ្លាមៗតែម្តង។

-តាមអំណានចម្លើយជនរងគ្រោះឈ្មោះ [redacted] ហឿត បានឆ្លើយថា នៅថ្ងៃកើតហេតុវេលាម៉ោង ២០ និង ២០ នាទី ខ្លួនបានដើរចេញពីផ្ទះ ដែលនៅក្បែរទីតាំងលក់ម្ហូប នៅម្តុំត្រង់ផ្សារប៉ៀ បន្ទាប់ពីទិញបានខ្លួនបានដើរត្រឡប់ទៅផ្ទះវិញ ពេលដល់ចំណុចផ្លូវប្រសព្វស្តុបដេអិន ជនល្មើសបានជិះម៉ូតូមកអែបខាងស្តាំដៃរបស់ខ្លួន ហើយបានឆក់កាបូបស្ពាយពីស្មារបស់ខ្លួនបណ្តាលឱ្យខ្លួនដួលទៅលើថ្នល់ និងបណ្តាលឱ្យខ្លួនរងរបួស ចំណែកជនល្មើសបានជិះម៉ូតូរត់គេចខ្លួន តែសមត្ថកិច្ចចាប់ខ្លួនបាន និងបានប្រគល់សម្ភារៈរបស់ខ្លួនឱ្យខ្លួនវិញគ្រប់ចំនួន។

-ក្នុងរឿងនេះខ្លួនមិនប្តឹងទាមទារសំណង និងជម្ងឺចិត្តអ្វីទេ។

## សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ ចម្លើយជនរងគ្រោះ និងភស្តុតាងឯកសារនានាពាក់ព័ន្ធក្នុងសំណុំរឿង ឃើញថាជនជាប់ចោទឈ្មោះ [redacted] រចនា និង ជនជាប់ចោទឈ្មោះ [redacted] វាសនា ពិតជាបានប្រព្រឹត្តបទ លួចមានស្ថានទម្ងន់ទោស តាមបញ្ញត្តិមាត្រា ៣៥៣ មាត្រា៣៥៧ ក្រមព្រហ្មទណ្ឌ ប្រព្រឹត្តនៅចំណុចផ្លូវប្រសព្វស្តុបដេអិន ផ្លូវលេខ១២៨ សង្កាត់ផ្សារដេប៉ូទី៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ កាលពីថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០២១។

ហេតុនេះតំណាងអយ្យការសូមតម្កល់ការចោទប្រកាន់ទុកជាបានការដដែល និងប្តឹងសុំឱ្យតុលាការផ្តន្ទាទោសជនជាប់ចោទតាមច្បាប់។

## សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារជនជាប់ចោទ

-លោកមេធាវី [redacted] ឡុងឌី មេធាវីការពារជនជាប់ចោទ បានធ្វើសេចក្តីសន្និដ្ឋានការពារថា

Scanned with CamScanner

ជនជាប់ចោទជាមនុស្សល្ងង់ខ្លៅ ខ្វះការពិចារណា ដោយសារការលេងល្បែងភ្នាល់ចាញ់អស់ប្រាក់ ទើបឈានដល់ការប្រព្រឹត្តអំពើនេះ ម្យ៉ាងទៀតជនជាប់ចោទបានឆ្លើយសារភាពស្មោះត្រង់ និងទើបតែប្រព្រឹត្តជាលើកទីមួយ ហេតុដូចនេះសូមតុលាការមេត្តាពិចារណាផ្តល់ស្ថានសម្រាលទោសដល់ជនជាប់ចោទទាំងពីរនាក់តាមមាត្រា៩៣ និងមាត្រា៩៤ នៃក្រមព្រហ្មទណ្ឌ។

## <u>សំដីចុងក្រោយរបស់ជនជាប់ចោទ</u>

ជនជាប់ចោទឈ្មោះ [redacted] រធា និងជនជាប់ចោទឈ្មោះ [redacted] វាសនា បាននិយាយសំដីចុងក្រោយបង្អស់ថា សូមតុលាការមេត្តាបន្ធូរបន្ថយទោសដល់ខ្លួនផង។

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ

-ក្រោយពីបានស្តាប់អំណានចម្លើយជនរងគ្រោះ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានទោសរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារឱ្យជនជាប់ចោទ

-ក្រោយពីបានស្តាប់ជនជាប់ចោទនិយាយសំដីចុងក្រោយ

-ក្រោយពីបានពិនិត្យលើឯកសារ ភស្តុតាងនានា

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## <u>សំអាងហេតុ</u>

១-យោងតាមដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះរបស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងរាជធានីភ្នំពេញ និងឆ្លងតាមការសាកសួរដេញដោលនាពេលសវនាការ កំណត់បានថា កាលពីថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០២១ មានអំពើ លួចមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅចំណុចចំណុចផ្លូវប្រសព្វស្តុបដេអិន ផ្ទះលេខ១២៨ សង្កាត់ផ្សារដេប៉ូទី៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ ប្រាកដមែន។

២-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] រធា បានឆ្លើយថា នៅថ្ងៃកើតហេតុខ្លួននិងឈ្មោះ [redacted] វាសនា បន្ទាប់ពីលេងហ្គេមបាញ់ត្រី អស់ប្រាក់បាននាំគ្នាជិះម៉ូតូ មួយ គ្រឿង ម៉ាក វីវ៉ា ដើម្បីធ្វើសកម្មភាពឆក់ ដោយខ្លួនជាអ្នកបើកបរម៉ូតូ ពេលដល់កន្លែងកើតហេតុបានឃើញជនរងគ្រោះឈប់ម៉ូតូចូលទៅទិញម្ហូប ដោយជនរងគ្រោះបានទុកកាបូបស្ពាយ នៅលើម៉ូតូ ខ្លួនបានឈប់ម៉ូតូ ហើយឈ្មោះ [redacted] វាសនា បានដើរចូលទៅលួចយកកាបូបស្ពាយនោះ បន្ទាប់មកពួកខ្លួនបានជិះម៉ូតូរត់គេចខ្លួន ប៉ុន្តែត្រូវសមត្ថកិច្ចជិះម៉ូតូដេញតាម និងចាប់ឃាត់ខ្លួនបានភ្លាមៗតែម្តង។

៣-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] វាសនា បានឆ្លើយថា នៅថ្ងៃកើតហេតុខ្លួននិងឈ្មោះ [redacted] វាសនា បន្ទាប់ពីលេងហ្គេមបាញ់ត្រី អស់ប្រាក់បាននាំគ្នាជិះម៉ូតូ មួយ គ្រឿង ម៉ាក វីវ៉ា ដើម្បីធ្វើសកម្មភាពឆក់ ដោយឈ្មោះ [redacted] វាសនា ជាអ្នកបើកបរម៉ូតូ ចំណែកខ្លួនជិះនៅខាងក្រោយ ពេលដល់

Scanned with CamScanner

កន្លែងកើតហេតុបានឃើញជនរងគ្រោះឈប់ម៉ូតូ ចូលទៅទិញម្ហូប ដោយជនរងគ្រោះបានទុកកាបូបស្ពាយនៅលើម៉ូតូឈ្មោះ [redacted]វាសនា បានឈប់ម៉ូតូ ហើយខ្លួនបានដើរចូលទៅលួចយកកាបូបស្ពាយនោះតែម្តង បន្ទាប់មកពួកខ្លួនបានជិះម៉ូតូរត់គេចខ្លួន ប៉ុន្តែត្រូវសមត្ថកិច្ចជិះដេញតាម និងចាប់ឃាត់ខ្លួនបានភ្លាមៗតែម្តង។

៤-តាមចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] ហឿត បានឆ្លើយថា នៅថ្ងៃកើតហេតុវេលាម៉ោង ២០ និង ២០ នាទី ខ្លួនបានដើរចេញពីផ្ទះ ដែលនៅក្បែរទីតាំងលក់ម្ហូប នៅម្តុំត្រង់ផ្សារញ៉ែ បន្ទាប់ពីទិញបានខ្លួនបានដើរត្រឡប់ទៅផ្ទះវិញ ពេលដល់ចំណុចផ្លូវប្រសព្វស្តុបដេអិន ជនល្មើសបានជិះម៉ូតូមកអែបខាងស្តាំដៃរបស់ខ្លួន ហើយបានឆក់កាបូបស្ពាយពីស្មារបស់ខ្លួន បណ្តាលឱ្យខ្លួនដួលទៅលើថ្នល់និងបណ្តាលឱ្យខ្លួនរងរបួស ចំណែកជនល្មើសបានជិះម៉ូតូរត់គេចខ្លួន តែសមត្ថកិច្ចចាប់ខ្លួនបាន និងបានប្រគល់សម្ភារៈរបស់ខ្លួនឱ្យខ្លួនវិញគ្រប់ចំនួន។

៥-តាមចម្លើយរបស់ជនជាប់ចោទទាំងពីរនាក់បញ្ជាក់ថា ពួកខ្លួនបានលួចយកកាបូបស្ពាយរបស់ជនរងគ្រោះខណៈជនរងគ្រោះទុកកាបូបស្ពាយនោះនៅលើម៉ូតូ ជាចម្លើយដោះសារអហេតុផល ព្រោះជនរងគ្រោះបានបញ្ជាក់ថាខ្លួនបានស្ពាយកាបូបរបស់ខ្លួនជាប់នឹងស្មា ដើរទៅទិញម្ហូប ពេលកំពុងដើរត្រឡប់ទៅវិញជនជាប់ចោទបានធ្វើសកម្មភាពជិះម៉ូតូអែប និងបានឆក់កាបូបពីស្មារបស់ខ្លួនបណ្តាលឱ្យខ្លួនដួល ចម្លើយរបស់ជនរងគ្រោះស្របទៅនឹងស្ថានភាពជាក់ស្តែង ព្រោះនៅពេលកើតហេតុជនរងគ្រោះបានដើរទៅទិញម្ហូប ដូចនេះជនរងគ្រោះគ្មានហេតុផលទុកកាបូបរបស់ខ្លួនដែលមានសម្ភារៈមានតម្លៃចោលនៅលើម៉ូតូរបស់អ្នកដទៃដើម្បីចូលទៅទិញម្ហូបអាហារទេ ហេតុនេះចម្លើយដោះសាររបស់ជនជាប់ចោទគ្មានមូលដ្ឋានអាចឱ្យតុលាការពិចារណាបានទេ។

៦-អំពើរបស់ជនជាប់ចោទឈ្មោះ [redacted]ចនា និងជនជាប់ចោទឈ្មោះ [redacted] វាសនា ដែលបានប្រព្រឹត្តអំពើហិង្សាទៅលើជនរងគ្រោះដើម្បីឆក់ហូតយកទ្រព្យសម្បត្តិពីជនរងគ្រោះដោយទុច្ចរិត តាមរយៈការឆក់កាបូបស្ពាយពីស្មារបស់ជនរងគ្រោះដោយបង្ខំ ខណៈជនរងគ្រោះកំពុងដើរឆ្លងកាត់ផ្លូវ រហូតបានបណ្តាលឱ្យជនរងគ្រោះរងរបួស មានធាតុផ្សំជាបទ លួចមានស្ថានទម្ងន់ទោស ដូចបញ្ញត្តិតាមមាត្រា ៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ។

៧-ជនជាប់ចោទឈ្មោះ [redacted] រចនា និងជនជាប់ចោទឈ្មោះ [redacted]វាសនា ជានីតិជនមានសមត្ថភាព និងស្មារតីគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវចំពោះអំពើប្រព្រឹត្តរបស់ខ្លួន។

៨-សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ មានមូលហេតុ និងមូលដ្ឋានគ្រប់គ្រាន់បញ្ជាក់ពីពិរុទ្ធភាពរបស់ជនជាប់ឈ្មោះ [redacted]ចនា និងជនជាប់ចោទឈ្មោះ [redacted] វាសនា ពីបទ លួចមានស្ថានទម្ងន់ទោស តាមបញ្ញត្តិមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ ប្រព្រឹត្តនៅចំណុចផ្លូវប្រសព្វស្តុបដេអិន ផ្លូវលេខ១២៨ សង្កាត់ផ្សារដេប៉ូទី៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ កាលពីថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០២១។

Scanned with CamScanner

៩-ជនរងគ្រោះឈ្មោះ[redacted] ហៀត មិនប្តឹងទាមទារសំណងការខូចខាត និងសំណងជម្ងឺចិត្តទេ ដូចនេះតុលាការមិនពិចារណាលើបញ្ហានេះឡើយ។

១០-វត្ថុចាប់យកមានដូចក្នុងកំណត់ហេតុទទួលវត្ថុចាប់យកលេខ ២០៤០ វ.ប.ត ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២១ មាន ម៉ូតូ ម៉ាក SUZUKI VIVA ពណ៌ខ្មៅ ពាក់ផ្លាកលេខ ភ្នំពេញ 1CC- 7657 ចំនួន ១ គ្រឿង ដែលជនជាប់ចោទបានប្រើប្រាស់ជាមធ្យោបាយប្រព្រឹត្តបទល្មើស គប្បីរឹបអូសជាសម្បត្តិរដ្ឋ។

១១-មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] រចនា និងជនជាប់ចោទឈ្មោះ [redacted] វាសនា ពីបទ លួចមានស្ថានទម្ងន់ទោស តាមបញ្ញត្តិមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ ប្រព្រឹត្តនៅចំណុចផ្លូវប្រសព្វស្តុបដេអិន ផ្លូវលេខ១២៨ សង្កាត់ផ្សារដេប៉ូទី៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ កាលពីថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០២១។

## <u>ហេតុដូច្នេះសម្រេច</u>

១/-ផ្តន្ទាទោសឈ្មោះ[redacted] រចនា ហៅ សីហា ភេទប្រុស អាយុ ២៧ ឆ្នាំ និងឈ្មោះ[redacted] វាសនា ហៅ ស្លា ភេទប្រុស អាយុ ២៨ ឆ្នាំ ដាក់ពន្ធនាគារក្នុងម្នាក់ៗកំណត់ ៥ (ប្រាំ) ឆ្នាំ។

ពីបទ លួចមានស្ថានទម្ងន់ទោស តាមបញ្ញត្តិមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ ប្រព្រឹត្តនៅចំណុចផ្លូវប្រសព្វស្តុបដេអិន ផ្លូវលេខ១២៨ សង្កាត់ផ្សារដេប៉ូទី៣ ខណ្ឌទួលគោករាជធានីភ្នំពេញ កាលពីថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០២១។

២/-វត្ថុចាប់យកមានដូចក្នុងកំណត់ហេតុទទួលវត្ថុចាប់យកលេខ ២០៤០ វ.ប.ត ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២១ មាន ម៉ូតូ ម៉ាក SUZUKI VIVA ពណ៌ខ្មៅ ពាក់ផ្លាកលេខ ភ្នំពេញ 1CC- 7657 ចំនួន ១ គ្រឿង រឹបអូសជាសម្បត្តិរដ្ឋ។

-សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២២ ចំពោះមុខជនជាប់ចោទ ប្រកាសជាសាធារណៈនៅថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០២២។

-គូភាគីមានសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងរយៈពេលដែលច្បាប់កំណត់។

| ក្រឡាបញ្ជីសវនាការ | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
| --- | --- | --- | --- |
| ហត្ថលេខា និងត្រា[redacted] | ហត្ថលេខា និងត្រា[redacted] | ហត្ថលេខា និងត្រា[redacted] | ហត្ថលេខា និងត្រា[redacted] |

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃចន្ទ ១៤កើត ខែជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២២

បានឃើញ
ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

[redacted]

ក្រឡាបញ្ជី

[redacted]